



# តើចំណុចដែលត្រូវបញ្ញត្តក្នុង ច្បាប់មានអ្វីខ្លះ?


ខែកុម្ភៈ ឆ្នាំ២០១៩
ក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន
វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ
អូនីស៊ិ ហ៊ិរ៉ូមិឈិ

February 2019
Hiromichi Onishi
Professor
International Cooperation Department
Research and Training Institute
Ministry of Justice of Japan

# តើចំណុចដែលត្រូវបញ្ញត្តក្នុងច្បាប់មានអ្វីខ្លះ?

## តើលិខិតបទដ្ឋានគតិយុត្តមានអ្វីខ្លះ?

- ទម្រង់នៃលិខិតបទដ្ឋានគតិយុត្តដែលមាននៅប្រទេសជប៉ុន
- **ថ្នាក់ជាតិ**: រដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ បទបញ្ជាផ្ទៃក្នុងរបស់សភា បទប្បញ្ញត្តិផ្ទៃក្នុងរបស់តុលាការកំពូល បទបញ្ជា ឬ ប្រកាសរបស់ខុទ្ទកាល័យ
- **រដ្ឋបាលថ្នាក់ក្រោមជាតិ**: ដីកាដែលចេញដោយក្រុមប្រឹក្សាខេត្ត<br>ដីកាដែលចេញដោយរដ្ឋបាលខេត្ត
- បទបញ្ជាផ្ទៃក្នុងរបស់សភា បទប្បញ្ញត្តិផ្ទៃក្នុងរបស់តុលាការកំពូល និង ដីកាដែលចេញដោយក្រុមប្រឹក្សាខេត្ត គឺជាការលើកលែងដោយសភាដែលជាស្ថាប័ននីតិប្បញ្ញត្តិរួម ផ្អែកតាមរដ្ឋធម្មនុញ្ញ។

# តើចំណុចដែលត្រូវបញ្ញត្តក្នុងច្បាប់មានអ្វីខ្លះ ?

## តើលិខិតបទដ្ឋានគតិយុត្តមានអ្វីខ្លះ ?

- ទម្រង់នៃលិខិតបទដ្ឋានគតិយុត្តដែលមាននៅក្នុងប្រទេសជប៉ុន
- ទំនាក់ទំនងទៅវិញទៅមកនៃទម្រង់ច្បាប់ជាតិ



# តើចំណុចដែលត្រូវបញ្ញត្តក្នុងច្បាប់មានអ្វីខ្លះ?

## តើលិខិតបទដ្ឋានគតិយុត្តមានអ្វីខ្លះ?

- ការតាក់តែងច្បាប់រដ្ឋបាលគឺជា៖
- វិធានច្បាប់ដែលបង្កើតឡើងដោយស្ថាប័នរដ្ឋបាល (បទបញ្ជារដ្ឋបាល)
- បទបញ្ជារដ្ឋបាលដែលមាននៅក្នុងប្រទេសជប៉ុន
- អនុក្រឹត្យ(គណៈរដ្ឋមន្ត្រី) បទបញ្ជា(នាយករដ្ឋមន្ត្រី) ប្រកាស(រដ្ឋមន្ត្រីទទួលបន្ទុក) បទប្បញ្ញត្តិ(គណៈកម្មការ និងការិយាល័យផ្សេងទៀត ក្រុមប្រឹក្សាភិបាលសវនកម្ម ក្រុមប្រឹក្សាធនធានមនុស្ស) បទប្បញ្ញត្តិ (ប្រធានស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ)

# តើចំណុចដែលត្រូវបញ្ញត្តក្នុងច្បាប់មានអ្វីខ្លះ?

## តើលិខិតបទដ្ឋានគតិយុត្តមានអ្វីខ្លះ?

- បទបញ្ញា និងបញ្ញត្តិច្បាប់
  - វិធានដែលទាក់ទងនឹងសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ ( "បញ្ញត្តិច្បាប់" )
  - មានលក្ខណៈជាបញ្ញត្តិច្បាប់
  - ឧទាហរណ៍៖ អនុក្រឹត្យ  បទបញ្ជា ឬ ប្រកាសរបស់ខុទ្ទកាល័យ
- បទបញ្ញាផ្ទៃក្នុងរដ្ឋបាល
  - វិធានដែលកំណត់បទដ្ឋានផ្ទៃក្នុងរបស់រដ្ឋបាល
  - ពុំមានលក្ខណៈជាបញ្ញត្តិច្បាប់
  - ឧទាហរណ៍៖ សេចក្តីបង្គាប់របស់ថ្នាក់លើ  សេចក្តីជូនដំណឹង

# តើចំណុចដែលត្រូវបញ្ញត្តក្នុងច្បាប់មានអ្វីខ្លះ?

ការតាក់តែងច្បាប់រដ្ឋបាល គឺជា៖

- ប្រភេទនៃបទបញ្ញាបញ្ញត្តិច្បាប់
- បទបញ្ញាអនុវត្ត
  - គឺជាបទបញ្ញាដែលកំណត់អំពីចំណុចសំខាន់ដើម្បីធ្វើការអនុវត្តច្បាប់ឲ្យបានជាក់លាក់ ដោយផ្អែកលើច្បាប់ដែលមាន។
- បទបញ្ញាបង្កើតតាមការកំណត់
  - បទបញ្ញាដែលបង្កើតឡើងតាមការកំណត់របស់ច្បាប់
- បទបញ្ញាឯករាជ្យ
  - បទបញ្ញាដែលស្ថាប័នរដ្ឋបាលបង្កើតឡើងដោយឯករាជ្យពីសភា→ផ្ទុយពីរដ្ឋធម្មនុញ្ញ

# តើចំណុចដែលត្រូវបញ្ញត្តក្នុងច្បាប់មានអ្វីខ្លះ?

ការតាក់តែងច្បាប់(ច្បាប់) គឺជា៖

- ការបង្កើតវិធានច្បាប់ដែលកំណត់ដោយសភា(ការតាក់តែងច្បាប់ដែលមានខ្លឹមសារបែបទម្រង់)
- ការបង្កើតវិធានច្បាប់ដែលមានលក្ខណៈទូទៅ និងលក្ខណៈអរូបិយ(ការតាក់តែងច្បាប់ដែលមានខ្លឹមសារជាសារធាតុ)
- ច្បាប់ត្រូវបានអនុវត្តដោយស្មើគ្នាចំពោះបុគ្គលគ្រប់រូប ហើយបុគ្គលគ្រប់រូបអាចដឹងអំពីលទ្ធផលដែលនឹងកើតមានឡើងក្នុងករណីច្បាប់ត្រូវបានយកមកអនុវត្ត ។ ហេតុនេះ សេដ្ឋកិច្ចនឹងអភិវឌ្ឍន៍ទៅមុខដោយរលូន។

# តើចំណុចដែលត្រូវបញ្ញត្តក្នុងច្បាប់មានអ្វីខ្លះ?

## តើចំណុចបែបណាដែលត្រូវបញ្ញត្តក្នុងច្បាប់?

- ការទាមទារផ្អែកតាមរដ្ឋធម្មនុញ្ញនៃប្រទេសជប៉ុន
- ការធានាសិទ្ធិលើទ្រព្យសម្បត្តិ
  - ខ្លឹមសារនៃសិទ្ធិលើទ្រព្យសម្បត្តិ ត្រូវចែងនៅក្នុងច្បាប់ ដើម្បីឲ្យស្របទៅនឹងសុខុមាលភាពសាធារណៈ(រដ្ឋធម្មនុញ្ញ មាត្រា២៩ កថាខណ្ឌទី២)។
- គោលការណ៍ច្បាប់ដែលកំណត់អំពីទោស
  - គ្មានជនណាម្នាក់ត្រូវបានដកហូតជីវិត ឬ សេរីភាព ឬ ត្រូវបានផ្តន្ទាទោសឡើយ ប្រសិនបើមិនមាននីតិវិធីដែលកំណត់ដោយច្បាប់(រដ្ឋធម្មនុញ្ញ មាត្រា៣១)។
  - បង្កើតអនុក្រឹត្យដើម្បីអនុវត្តរដ្ឋធម្មនុញ្ញ និងបញ្ញត្តិច្បាប់ ប៉ុន្តែនៅក្នុងអនុក្រឹត្យ មិនអាចបង្កើតបទប្បញ្ញត្តិស្តីពីការដាក់ពិន័យទេ លើកលែងតែក្នុងករណីដែលមានការចង្អុលបង្ហាញជាពិសេសពីច្បាប់ (រដ្ឋធម្មនុញ្ញមាត្រា៧៣ ចំណុច ច វាក្យខណ្ឌទី២)។
- គោលការណ៍ច្បាប់ស្តីពីពន្ធ
  - ចំពោះការយកពន្ធថ្មី ឬ ការផ្លាស់ប្តូរពន្ធបច្ចុប្បន្ន ចាំបាច់ត្រូវផ្អែកតាមច្បាប់ ឬ លក្ខខណ្ឌដែលច្បាប់បានកំណត់ (រដ្ឋធម្មនុញ្ញ មាត្រា៨៤)។

# តើចំណុចដែលត្រូវបញ្ញត្តក្នុងច្បាប់មានអ្វីខ្លះ?

## តើចំណុចបែបណាដែលត្រូវបញ្ញត្តក្នុងច្បាប់?

- ចំណុចដែលកម្រិតដោយផ្ទាល់នូវសិទ្ធិ និង ចំណុចដែលដាក់កាតព្វកិច្ចទៅលើប្រជាពលរដ្ឋ ត្រូវមានចែងក្នុងច្បាប់( គោលការណ៍ Statutory Reservations )

- វិធានច្បាប់ដែលទាក់ទងនឹងយន្តការគ្រប់គ្រងរដ្ឋ(វិធានស្តីពីការបង្កើត និងគ្រប់គ្រងអង្គការ )

# តើចំណុចដែលត្រូវបញ្ចូលក្នុងច្បាប់មានអ្វីខ្លះ?

## តើត្រូវពិចារណាលើចំណុចណាខ្លះ នៅពេលធ្វើសេចក្តីព្រាង?

- ភាពសមស្របទៅនឹងគោលនយោបាយ
  - អត្ថិភាព ឬ ភាពសមរម្យនៃអង្គហេតុក្នុងការតាក់តែងច្បាប់
  - ភាពសមហេតុផល ឬ ភាពសមរម្យនៃគោលបំណង ឬ មធ្យោបាយ
  - អានុភាពអនុវត្ត ឬ លទ្ធភាពដែលអាចអនុវត្តជាក់ស្តែងនៃគោលបំណង ឬ មធ្យោបាយ

- ការសម្របទៅតាមច្បាប់
  - ការរក្សានូវការសម្របទៅតាមបទដ្ឋានគតិយុត្តដែលមានលំដាប់ខ្ពស់
  - ការរក្សានូវការសម្របទៅតាមបទដ្ឋានគតិយុត្តដែលមានលំដាប់ដូចគ្នា



- បច្ចេកទេសតាក់តែងច្បាប់ ដែលត្រូវបានបង្កើតឡើង